## រាជបណ្ឌិត្យសភាកម្ពុជា

### វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ

*អត្ថបទស្រាវជ្រាវ ស្តីពី*

# សហគមន៍ខ្មែរអ៊ិស្លាម(ជ្វា)នៅខេត្តកំពត

# ករណីសិក្សា៖ ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត



*ដោយ៖ ម៉ិល វាសនា*

*មន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា*

*ខែកុម្ភៈ ឆ្នាំ២០១៩*

# សហគមន៍ខ្មែរអិស្លាម (ជ្វា) នៅខេត្តកំពត
# ករណីសិក្សា៖ ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត

## សេចក្តីផ្តើម

*នៅកម្ពុជា នៅពេលគេលើកឡើងអំពីសាសនិកគោរពប្រតិបត្តិសាសនាអិស្លាម គឺគេតែងគិតសំដៅដល់ជនជាតិចាមដែលមានប្រភពកំណើតនៅប្រទេសចម្ប៉ា ហើយដែលបានធ្វើអន្តោប្រវេសន៍មករស់នៅក្នុងដែនរដ្ឋកម្ពុជានៅអំឡុងសតវត្សរ៍ទី១៥*[១] *បន្ទាប់ពីប្រទេសនេះត្រូវវាយយកគ្រប់គ្រងដោយវៀតណាម។ ប៉ុន្តែ វាពុំមែនបែបនេះឡើយ។ នៅមានជនជាតិទីទៃពីជនជាតិចាមដែលគោរពប្រតិបត្តិសាសនាអិស្លាម ហើយដែលបានមករស់នៅក្នុងដែនរដ្ឋកម្ពុជាដែរ នោះគឺជាជនជាតិជ្វាដែលបានធ្វើអន្តោប្រវេសន៍ពីកោះជ្វា ប្រទេសឥណ្ឌូនេស៊ី មករស់នៅកម្ពុជាតាមតំបន់មាត់សមុទ្រ ជាពិសេសនៅខេត្តកំពត។ មានឯកសារបញ្ជាក់ថា ជ្វា ប្រហែលមករស់នៅក្នុងកម្ពុជានៅសតវត្សទី១៣*[២]*។*

*អត្ថបទនេះនឹងព្យាយាមបកស្រាយបញ្ជាក់លើអំណះអំណាងខាងលើ តាមរយៈការសិក្សាស្រាវជ្រាវលើសហគមន៍សាសនិកអិស្លាម នៅឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត ដែលជាឃុំមានសាសនិកអិស្លាមរស់នៅច្រើនជាងគេក្នុងខេត្តកំពត ហើយការសិក្សាស្រាវជ្រាវនេះ គឺផ្តោតលើប្រវត្តិ ទំនៀមទម្លាប់ប្រពៃណី និង ការប្រតិបត្តិសាសនាអិស្លាមរបស់សហគមន៍នេះ។*

## ១. ប្រវត្តិសហគមន៍ខ្មែរអិស្លាម (ជ្វា) នៅខេត្តកំពត

*ខ្មែរអិស្លាមនៅខេត្តកំពតយល់ថា ខ្លួនមានប្រភពកំណើតពីជាតិសាសន៍តែមួយជាមួយគ្នា។ ពួកគាត់សុទ្ធសឹងបានដឹងនូវការតំណាលតៗគ្នាអំពីប្រភពនៃអត្តិភាពរបស់ក្រុមខ្លួននៅកម្ពុជា។ ការតំណាលនោះមានសេចក្តីថា*[៣] ដំបូងឡើយ មានអ្នកនេសាទឬអ្នកជំនួញបានធ្វើដំណើរតាមផ្លូវសមុទ្រពីកោះស៊ូម៉ាត្រា ប្រទេសឥណ្ឌូនេស៊ី មករស់នៅតំបន់មាត់សមុទ្រក្នុងខេត្តកំពត នៃប្រទេសកម្ពុជា។ អ្នកនេសាទឬអ្នកជំនួញនោះ (ខ្លះថា ជាបុរសមានតែម្នាក់ឯង ឯខ្លះថា មានពីរនាក់ប្តីប្រពន្ធ ហើយមានកូនតៗមក) បានរៀបការជាមួយនារីខ្មែរ ហើយក៏បានបង្កើតជាកូន ពូន

[១] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់៖ *ក្រុមជនជាតិភាគតិចនៅកម្ពុជា* បោះពុម្ពលើកទី២ ២០១៥ ទំព័រ៣៤។
[២] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់៖ ក្រុមជនជាតិភាគតិចនៅកម្ពុជា បោះពុម្ពលើកទី២ ២០១៥ ទំព័រ៣៤។
[៣] *លី សារី* គណៈអ៊ីម៉ាំខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧)។

*ជាចៅជាបន្តបន្ទាប់មករហូតដល់សព្វថ្ងៃនេះ។ ភាគច្រើន ពួកគេប្រកបរបរចិញ្ចឹមជីវិតដោយការនេសាទសមុទ្រ*[៤] ។

*ទោះបីជាសេចក្តីតំណាលតៗគ្នានេះហាក់ពុំសូវមានភាពច្បាស់លាស់ក៏ដោយ តែវាបានបង្ហាញនូវភាពរួមជាមូលដ្ឋានពីរគឺ សហគមន៍សាសនិកអ៊ិស្លាមនៅខេត្តកំពតមានប្រភពមកពីប្រទេសឥណ្ឌូនេស៊ី មិនមែនប្រទេសចម្ប៉ានិងសហគមន៍សាសនិកអ៊ិស្លាមនៅខេត្តកំពតកើតឡើងតាមរយៈការរៀបការជាមួយនារីខ្មែរ។ ការណ៍នេះធ្វើឱ្យសាសនិកអ៊ិស្លាមទាំងឡាយនៅខេត្តកំពតមានអារម្មណ៍ថា ខ្លួនមានឈាមជ័រ មានចរិតលក្ខណៈជាខ្មែរ ដែលដូនតារបស់ខ្លួនបានរៀបការជាមួយអន្តោប្រវេសន៍ជនពីប្រទេសឥណ្ឌូនេស៊ីដែលគោរពប្រតិបត្តិសាសនាអ៊ិស្លាម។*

*ប្រហាក់ប្រហែលគ្នានឹងសេចក្តីតំណាលតៗគ្នានេះដែរ* «ប្រវត្តិសាស្ត្របានបង្ហាញថា ពួកជ្វា (ម៉ាឡេ) មានអត្ថិភាពនៅកម្ពុជាអស់ជាច្រើនសតវត្សរ៍មកហើយ តាមរយៈការធ្វើជំនួញពីប្រទេសម៉ាឡេឬឧបទ្វីបឥណ្ឌូនេស៊ី។ វាទំនងច្រើនដែលថាជ្វាទាំងនោះភាគច្រើនជាបុរស ដែលខុសពីក្រុមអន្តោប្រវេសន៍ចាម។ ប្រសិនបើបុរសជ្វាជាអ្នកជំនួញរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីខ្មែរ នោះកូនដែលកើតមកត្រូវគោរពប្រតិបត្តិសាសនាអ៊ិស្លាមតាមឪពុក តែអាចនិយាយភាសាខ្មែរតាមម្តាយ។ ហេតុនេះ ក្រុមមូស្លីមជ្វា (មូស្លីមគឺអ្នកគោរពប្រតិបត្តិសាសនាអ៊ិស្លាម) នៅខេត្តកំពតទំនងជាមានដើមកំណើតជាកូនកាត់ខ្មែរ-ម៉ាឡេ។ សហគមន៍នេះស្ថិតនៅតាមតំបន់ឆ្នេរសមុទ្រនៃប្រទេសកម្ពុជា ជាទីផ្សារពាណិជ្ជកម្មជាមួយអ្នកធ្វើដំណើរតាមជើងទឹកពីប៉ាតានី និងកេឡាន់តាន់ នៅខាងឈូងសមុទ្រថៃ [៥]»។

*ទាំងតាមរឿងតំណាលតៗគ្នា ទាំងតាមប្រវត្តិសាស្ត្រ សុទ្ធសឹងបានបង្ហាញនូវទិដ្ឋភាពដូចគ្នាអំពីប្រភពអត្ថិភាពនៃសហគមន៍សាសនិកអ៊ិស្លាមនៅខេត្តកំពត នោះគឺ សាសនិកអ៊ិស្លាមនៅខេត្តកំពតពុំមែនមានប្រភពពីជនជាតិចាមដែលបានធ្វើអន្តោប្រវេសន៍ពីប្រទេសចម្ប៉ាទេ តែក្រុមនេះមានប្រភពមកពីប្រទេសម៉ាឡេឬឥណ្ឌូនេស៊ី។ ជាក់ស្តែង ក្រុមសាសនិកអ៊ិស្លាមនៅខេត្តកំពតសុទ្ធសឹងប្រកាន់នៅក្នុងគំនិតថា ក្រុមខ្លួនជាជ្វាកាត់ខ្មែរ មិនមែនជាចាមទេ ហើយក៏ពុំមានសមានចិត្តសោកស្តាយនឹងប្រវត្តិសាស្ត្រនៃការបាត់បង់ប្រទេសចម្ប៉ាក្នុងនាមជាម្ចាស់ប្រទេសនេះដែរ។*

*តាមរយៈកិច្ចសម្ភាសន៍ លោក លី សារី*[៦] *ដែលជាគណៈអ៊ីម៉ាំ ខេត្តកំពត បានលើកឡើងថា* «កន្លងមក មានអ្នកនយោបាយមួយចំនួន បានបញ្ចុះបញ្ចូលពួកខ្ញុំទាក់ទងនឹងការដណ្តើមមកវិញនូវទឹកដីចម្ប៉ាដែលបច្ចុប្បន្នស្ថិតក្នុងទឹកដីវៀតណាម។ ប៉ុន្តែ ពួកខ្ញុំរស់នៅទីនេះមិនមានប្រតិកម្មនោះទេ ព្រោះពួកខ្ញុំដឹងថា ចម្ប៉ាមិនមែនជាប្រទេសកំណើតរបស់ពួកខ្ញុំនោះទេ» ។ *ក្រុមនេះចូលចិត្តឱ្យគេហៅក្រុមខ្លួនថា «ខ្មែរអ៊ិស្លាម»*

---

[៤] *លី សារី* គណៈអ៊ីម៉ាំខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧)

[៥] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់៖ *ក្រុមជនជាតិភាគតិចនៅកម្ពុជា* បោះពុម្ពលើកទី២ ២០១៥ ទំព័រ៨៨

[៦] *លី សារី* គណៈអ៊ីម៉ាំខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧)

*ដែលបញ្ញត្តិនេះ បង្កើតឡើងនៅក្នុងសម័យសង្គមរាស្ត្រនិយម ដោយសម្តេចព្រះបាទ នរោត្តម សីហនុ ក្នុងគោលបំណងបង្រួបបង្រួមគ្រប់ជាតិសាសន៍ទាំងអស់នៅក្នុងទឹកដីកម្ពុជា។ ព្រះអង្គបានប្រើបញ្ញត្តិ «ខ្មែរអ៊ិស្លាម» ហៅសំដៅលើសហគមន៍ចាម-ម៉ាឡេរស់នៅកម្ពុជា។*

*ជាទូទៅ ក្រុមសាសនិកអ៊ិស្លាមនៅខេត្តកំពតពុំចេះនិយាយភាសាចាមទេ តែពួកគេបានប្រើភាសាខ្មែរក្នុងទំនាក់ទំនងជីវភាពប្រចាំថ្ងៃ។* «ពួកខ្ញុំនៅទីនេះមិននិយាយភាសាចាមទេ ហើយក៏មិនមានអ្នកចេះភាសាចាមដែរ ប៉ុន្តែ បើមានអ្នកចេះក៏តិចតួចបំផុត ហើយពួកគាត់ទៅរៀនពីខាងចាមនៅស្រុកក្រូចឆ្មា ខេត្តកំពង់ចាម ដោយគ្រាន់តែចង់ចេះចង់ដឹងប៉ុណ្ណោះ»[៧]។ *សហគមន៍នេះក៏ប្រើភាសាម៉ាឡេ និងភាសាអារ៉ាប់ក្នុងការសិក្សារៀនសូត្រគម្ពីរសាសនាអ៊ិស្លាមដែរ*[៨]*។ ក្នុងចំណោមភាសាខ្មែរ ភាសាម៉ាឡេនិងភាសាអារ៉ាប់ ពួកគេចេះនិយាយភាសាខ្មែរនិងភាសាម៉ាឡេបានយ៉ាងស្ទាត់ជំនាញ។ ដោយមានគម្ពីរសាសនាអ៊ិស្លាមជាភាសាម៉ាឡេ (ប្រទេសម៉ាឡេស៊ីបានបកប្រែគម្ពីរសាសនាអ៊ិស្លាមពីភាសាអារ៉ាប់មកជាភាសាម៉ាឡេ) ក្រុមនេះបានសិក្សាសាសនាអ៊ិស្លាម ជាភាសាម៉ាឡេ។ ភាសាម៉ាឡេធ្វើឱ្យគេរៀនងាយយល់និងរៀនឆាប់ចេះជាងភាសាអារ៉ាប់ ព្រោះពាក្យក្នុងភាសាម៉ាឡេ គឺមានតែ ២០០០ពាក្យប៉ុណ្ណោះ ពេលភាសាអារ៉ាប់មានរហូតដល់ ១៧០០០ពាក្យ*[៩]*។ ទោះយ៉ាងណានៅក្នុងគម្ពីរជាភាសាម៉ាឡេនោះ ក៏នៅមានលាយភាសាអារ៉ាប់ខ្លះដែរ ជាពិសេសឈ្មោះនៃពិធីសាសនា មានជាអាទិ៍ បុណ្យម៉ៅឡូត់ សឡាត ជាដើម។*

*សហគមន៍ខ្មែរអ៊ិស្លាម(ជ្វា)នៅខេត្តកំពតមានលក្ខណៈរបៀបគ្នានឹងសហគមន៍សាសនិកអ៊ិស្លាម(ចាម)ដទៃទៀតនៅកម្ពុជាដែរ។ លក្ខខណ្ឌសាសនា សង្គម និង ទំនៀមទម្លាប់ប្រពៃណីធ្វើឱ្យសហគមន៍សាសនិកអ៊ិស្លាមត្រូវរស់នៅជាក្រុម ជាភូមិ និង ជាតំបន់ ដាច់ដោយឡែកពីប្រជាជនខ្មែរ។ ប៉ុន្តែ ពួកគេនៅរក្សាទំនាក់ទំនងក្នុងជីវភាពប្រចាំថ្ងៃធម្មតាជាមួយប្រជាជនខ្មែរ។*

*ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគ្រប់ទម្រង់នៃការប្រតិបត្តិជំនឿសាសនាក្នុងសង្គមត្រូវលុបបំបាត់ចោលទាំងអស់ ហើយសហគមន៍ខ្មែរអ៊ិស្លាម(ជ្វា)នៅខេត្តកំពត ក៏មានវាសនាដូចគ្នានឹងប្រជាជនទូទៅដែរ។ វិហារទាំងឡាយរបស់សហគមន៍ខ្មែរអ៊ិស្លាម(ជ្វា)ក្នុងខេត្តកំពត ដែលប្រើ*

---

[៧] *ស្លេះ ហ្គោសាលី* គ្រូបង្រៀនផ្នែកសាសនាអ៊ិស្លាមនៅសហគមន៍ព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១៧)។

[៨] បច្ចុប្បន្នមានការបកប្រែគម្ពីរសាសនាអ៊ិស្លាមពីភាសាម៉ាឡេមកជាភាសាខ្មែរសម្រាប់បង្រៀនដល់សាសនិកអ៊ិស្លាមនៅទូទាំងប្រទេសប្រទេស។

[៩] *ស្លេះ ហ្គោសាលី* គ្រូបង្រៀនផ្នែកសាសនាអ៊ិស្លាមនៅសហគមន៍ព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១៧)។

សម្រាប់ការគោរពថ្វាយបង្គំព្រះ ត្រូវពួក ប៉ុល ពត ប្រើជាឃ្លាំង ជាមន្ទីរឃុំឃាំង និង ជាកន្លែងដាក់ដី ជាដើម។ ជាងនេះទៀត ពួក ប៉ុល ពត បានរៀបចំផែនការសម្លាប់ក្រុមមូស្លីមទាំងនេះ ព្រោះពួកគេយល់ថា នៅពេលអនាគត មូស្លីមនៅទីនេះនឹងក្លាយទៅជាយួន[១០]។ ពួក ប៉ុល ពត បានរៀបចំធ្វើពិធីជួបជុំគ្នាមួយ ដោយមានការធ្វើនំបញ្ចុកហូបរួមគ្នាក្នុងគោលបំណងសម្លាប់ តែគម្រោងការសម្លាប់នេះត្រូវបរាជ័យ ដោយចំពេលប្រទេសបានរំដោះទាន់ពេលវេលា។ ទោះជាយ៉ាងណា គេបានសន្និដ្ឋានថា ខ្មែរអ៊ិស្លាម(ជ្វា)នៅខេត្តកំពតត្រូវសម្លាប់អស់ច្រើននាក់ផងដែរ[១១]។

បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវផ្តួលរំលំ សហគមន៍ខ្មែរអ៊ិស្លាម(ជ្វា)នៅខេត្តកំពតដូចជាប្រជាជននៅទូទាំងប្រទេសដែរ បានចាប់ផ្តើមឡើងវិញនូវគ្រប់សកម្មភាពជីវិត ដោយរួមទាំងការគោរពជំនឿ សាសនា និង ទំនៀមទម្លាប់ប្រពៃណីផ្សេងៗផង។ ពួកគេបានបោសសម្អាតវិហារនិងបរិវេណជុំវិញវិហារឡើងវិញ និង មូលមតិជួយគ្នាជួសជុលវិហារខូចឡើងវិញផងដែរ។

## ២. ទំនៀមទម្លាប់និងប្រពៃណី

### ២.១. សម្លៀកបំពាក់

ជាទូទៅ ខ្មែរអ៊ិស្លាមនៅសហគមន៍ឃុំព្រៃថ្នង ស្លៀកសម្លៀកបំពាក់មានលក្ខណៈប្រហាក់ប្រហែលនឹងខ្មែរដែរ ដែលធ្វើឱ្យគេពិបាកក្នុងការកំណត់សម្គាល់ខ្មែរអ៊ិស្លាមតាមរយៈសម្លៀកបំពាក់ណាស់។ បុរសច្រើនស្លៀកខោជើងវែង ពាក់អាវសឺមីឬអាវយឺតធម្មតា ដែលអាចរកទិញបានយ៉ាងងាយនៅតាមទីផ្សារ ហើយកម្រមានពាក់មួកកន្ទីបទៀតផង។ បុរសៗក៏អាចស្លៀកពាក់បែបនេះបាននៅពេលចូលវិហារថ្វាយបង្គំព្រះដែរ តែត្រូវមានពាក់មួកកន្ទីបលើក្បាលបន្ថែមទៀត[១២]។ ប៉ុន្តែ បុរសៗនៅក្នុងសហគមន៍ខ្មែរអ៊ិស្លាមនេះនិយមទុកពុកចង្កាដែលជាសញ្ញាណអាចឱ្យគេកត់សម្គាល់ បានថាជាខ្មែរអ៊ិស្លាម។ ដោយឡែក ស្ត្រីខ្មែរអ៊ិស្លាមនៅក្នុងសហគមន៍នេះក៏កម្រឃុំមុខមាត់និងស្លៀកសម្លៀកបំពាក់តាមប្រពៃណីមូស្លីមដែរ ដោយពួកគេមានការរស់នៅដោយសម្រុះខ្លួនច្រើននៅក្នុងសង្គមខ្មែរ។ ភាគច្រើនបំផុត ស្ត្រីស្លៀកពាក់តាមប្រពៃណីបែបមូស្លីមរបស់ខ្លួនតែនៅពេលមានពិធីត្រូវទៅវិហារប៉ុណ្ណោះ។ ស្ត្រីអ៊ិស្លាមដឹងគ្រប់គ្នាថា បើកាលណាពួកគេត្រូវទៅវិហារក្នុងកិច្ចពិធីឬដើម្បីថ្វាយបង្គំ នោះពួកគេត្រូវរៀបចំខ្លួនយ៉ាងសមរម្យ ដោយបាំងបិទខ្លួនឱ្យ

---

[១០] *សុខ សម៉ាឌុន* អ៊ីម៉ាំវិហារនៅភូមិទ្វារថ្មី ស្រុកទឹកឈូ ខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧)។

[១១] *លី សារី* គណៈអ៊ីម៉ាំខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧)។

[១២] ជាទូទៅ សាសនិកអ៊ិស្លាមតែងស្លៀកពាក់ដោយប្រយ័ត្នប្រយែងនិងសមរម្យតាមលក្ខណៈសាសនាក្នុងការចូលថ្វាយបង្គំក្នុងព្រះវិហារ។

ជិតនិងប្រយ័ត្នប្រយែងជាងធម្មតា។ ជារួមទោះបីបច្ចុប្បន្នមានស្ត្រីខ្មែរអ៊ិស្លាមស្លៀកខោខ៊ូឬសម្លៀកបំពាក់បែបទំនើបទាន់សម័យក្តី តែពួកគេដឹងថា គេត្រូវស្លៀកសម្លៀកបំពាក់តាមរបៀបរបបប្រពៃណីមូស្លីមនៅពេលចូលរួមកិច្ចពិធីផ្សេងៗនៅវិហារ។



សម្លៀកបំពាក់បុរសនិងនារីខ្មែរអ៊ិស្លាម(ជ្វា) ពេលមកវិហារ (សហគមន៍ព្រៃថ្នង ខេត្តកំពត)

## ២.២. អាពាហ៍ពិពាហ៍

ច្បាប់ក្នុងសាសនាអ៊ិស្លាមចែងថា បុរសម្នាក់អាចមានភរិយាបួននាក់ ប្រសិនបើបុរសនោះមានលទ្ធភាពអាចផ្តល់នូវភាពស្មើៗគ្នាដល់ស្ត្រីជាភរិយាទាំងបួននាក់នោះមានទាំងសេចក្តីស្រឡាញ់ និងទ្រព្យសម្បត្តិជាដើម។ ប៉ុន្តែ គេមិនអាចមានភរិយាលើសពីបួននាក់បាននោះទេ ក្នុងពេលជាមួយគ្នា។ ទោះបីជាមានច្បាប់សាសនាចែងអនុញ្ញាតបែបនេះក្តី តែបុរសខ្មែរអ៊ិស្លាមនៅក្នុងសហគមន៍នេះកម្រមានអ្នកមានភរិយាចាប់ពីពីរនាក់ឡើងទៅក្នុងពេលជាមួយគ្នាណាស់ ដោយម្យ៉ាង គេពិបាកនឹងសម្រេចបានតាមឱវាទសាសនាក្នុងការផ្តល់នូវភាពស្មើគ្នាដល់ភរិយាខ្លួន និងម្យ៉ាងទៀត ហើយដែលសំខាន់ គឺគេយល់ថាវានឹងមានបញ្ហានៅក្នុងគ្រួសារមិនខាន។ ជាមួយគ្នានេះ បុរសខ្មែរអ៊ិស្លាមទាំងនេះមានចរិតលក្ខណៈនិងឥរិយាបថរបៀបខ្មែរទៅហើយ ហើយម្យ៉ាង ការមានភរិយាលើសពីម្នាក់នៅក្នុងពេលតែមួយ គឺជារឿងខុសច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅសហគមន៍ខ្មែរអ៊ិស្លាម(ជ្វា)ខេត្តកំពត ទោះបីជាការរៀបអាពាហ៍ពិពាហ៍មានកិច្ចពិធីខុសគ្នាខ្លះទៅតាមទីកន្លែង តាមចំណូលចិត្តគ្រួសារ ឬតាមចំណូលចិត្តរបស់សាមីខ្លួនជាកូនក្រមុំ ឬកូនកំលោះក្តី តែជាទូទៅវាមានលក្ខណៈរួមរបស់វា។ មុនពេលឈានដល់ការរៀបអាពាហ៍ពិពាហ៍ គេប្រតិបត្តិនូវពិធីស្តីដណ្តឹង ដោយក្នុងពិធីនេះអាចមានជាពិធីបំពាក់ជញ្ជៀននិងមានការប្រគល់ថវិកាជូនខាងស្រី(ភ័ស្តុភារបណ្ណាការ)របៀបខ្មែរដែរ។ ប៉ុន្តែ ការរៀបអាពាហ៍ពិពាហ៍

របស់សហគមន៍ខ្មែរអ៊ិស្លាម(ជ្វា) មិនមានកិច្ចពិធីច្រើន មានជាអាទិ៍ ពិធីកាត់សក់ ពិធីសំពះផ្ទឹម និង ពិធីកាត់ខាន់ស្លា ... ដូចខ្មែរទេ។ ក្រៅពីនេះ ការរៀបអាពាហ៍ពិពាហ៍ខ្មែរត្រូវមានក្រុមភ្លេងការ និងមានចាក់មេក្រូជាហូរហែទៅតាមកិច្ចពិធីនីមួយៗជាដើម។

ការរៀបអាពាហ៍ពិពាហ៍របស់សហគមន៍សាសនិកខ្មែរអ៊ិស្លាមនៅឃុំព្រៃថ្នង ប្រព្រឹត្តទៅក្នុងរយៈពេល១ថ្ងៃ ហើយកិច្ចពិធីសំខាន់ក្នុងការរៀបអាពាហ៍ពិពាហ៍នេះ គឺ*ពិធីប្រគល់កូនក្រមុំឱ្យកូនកំលោះ*។ ពិធីនេះធ្វើឡើងដោយមិនមានកំណត់ម៉ោងវេលាឡើយ ដោយគេអាចធ្វើនៅពេលព្រឹក ពេលរសៀល ឬពេលល្ងាចក៏បាន។

ពិធីប្រគល់កូនក្រមុំឱ្យកូនកំលោះ ប្រព្រឹត្តទៅដោយឪពុកកូនក្រមុំចាប់ដៃកូនក្រមុំនិងកូនកំលោះ ហើយនិយាយថា «ខ្ញុំប្រគល់កូនក្រមុំរបស់ខ្ញុំឈ្មោះ «ក» ឱ្យទៅអ្នក (កូនកំលោះ) ប៉ុន្តែកូនក្រមុំរបស់ខ្ញុំមានតម្លៃខ្លួន តើអ្នក(កូនកំលោះ)ទទួលយកបានទេ?» បើកូនកំលោះឆ្លើយថា «ខ្ញុំទទួលយកបាន» នោះកិច្ចពិធីប្រគល់កូនក្រមុំឱ្យកូនកំលោះនឹងត្រូវបញ្ចប់ [១៣]។ ករណីខ្លះ ក៏មានការនិយាយ តថ្លៃគ្នារវាងឪពុកកូនក្រមុំនឹងកូនកំលោះលើតម្លៃខ្លួនរបស់កូនក្រមុំដែរ។ ប៉ុន្តែ ជាទូទៅតម្លៃខ្លួនកូនក្រមុំអាចមានរវាងពី ២០០ដុល្លារ ទៅ ៣០០ដុល្លារ ដោយមានការនិយាយដឹងគ្នាជាមុន។ តម្លៃ ខ្លួនកូនក្រមុំជាតម្លៃផ្សេងដោយឡែកពីក័ស្តុការបណ្ណាការជូនខាងកូនស្រី។

ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ក៏មានពិធីលៀងភោជនាហារជូនញាតិមិត្តជិតឆ្ងាយនិងភ្ញៀវកិត្តិយសដែលមកចូលរួមដែរ។ ជាមួយគ្នានេះដែរ ក៏មានការចាក់ឃោសនសព្ទ(ចាក់មេក្រូ)ជាចម្រៀងសម្រាប់កំដរបរិយាកាសផងដែរ។ ជាទូទៅ ចម្រៀងដែលចាក់ក្នុងពិធីមង្គលនេះ សុទ្ធសឹងជាចម្រៀងដែលច្រៀងជាភាសាម៉ាឡេនិងអារ៉ាប់ ហើយដែលមានខ្លឹមសារអប់រំ ណែនាំ រៀបរាប់អំពីការធ្វើអំពើល្អ ដោយមិនផ្តោតលើការសប្បាយរីករាយឡើយ។

បច្ចុប្បន្ននេះ ពិធីរៀបអាពាហ៍ពិពាហ៍របស់សហគមន៍ខ្មែរអ៊ិស្លាមនៅឃុំព្រៃថ្នង ក៏មានការវិវត្តដោយទទួលឥទ្ធិពលពីបរិយាកាសនៃសង្គមខ្មែរ និងដោយការនិយមចូលចិត្តរបស់គ្រួសារនិងសាមីខ្លួនជាកូនក្រមុំ-កូនកំលោះដែរ។ គ្រួសារខ្លះបានរៀបអាពាហ៍ពិពាហ៍ដោយរៀបចំមានពិធីហែជំនូន មានការសម្អាង មានអ្នកកំដរកូនក្រមុំ និង មានអ្នកកំដរកូនកម្លោះ ដែលលក្ខណៈទាំងនេះមិនមានការប្រតិបត្តិឬជាកាតព្វកិច្ចនៅក្នុងសហគមន៍ខ្មែរអ៊ិស្លាមនេះពីមុនមកទេ។ ទោះជាយ៉ាងណា ការប្រតិបត្តិបែបនេះមិនមានលក្ខណៈជាទូទៅឡើយ ដោយគ្រួសារខ្លះនៅបន្តការរៀបអាពាហ៍ពិពាហ៍កូនប្រុស-ស្រីរបស់ខ្លួនតាមលក្ខណៈសាសនានៅឡើយ។

---

[១៣] *ស្លេះ ហ្គោសាលី* គ្រូបង្រៀនផ្នែកសាសនាអ៊ិស្លាមនៅឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧)។

### ២.៣. ពិធីបុណ្យសព និងការទុកដាក់សព

នៅសហគមន៍ខ្មែរអ៊ិស្លាម(ជ្វា)ខេត្តកំពត ជាពិសេសសហគមន៍ខ្មែរអ៊ិស្លាមនៅឃុំព្រៃថ្នង សាច់ញាតិតែងមានរៀបចំកិច្ចពិធីជូនដំណើរសពជាសមាជិកគ្រួសាររបស់ខ្លួន ទៅតាមប្រពៃណី និងច្បាប់នៃសាសនាអ៊ិស្លាម។ គេមិនមានការចាក់ភ្លេងកំដរនៅកំលុងពេលនៃកិច្ចពិធីជូនដំណើរសពឡើយ។ ទន្ទឹមនឹងនោះ តាមច្បាប់សាសនាអ៊ិស្លាម គ្រួសារសពមិនមានភារកិច្ចត្រូវរៀបចំចំណីអាហារដើម្បីទទួលអ្នកចូលរួមកិច្ចពិធីនេះឡើយ ដោយគ្រួសារសពកំពុងមានទុក្ខ។ ផ្ទុយទៅវិញ គឺភ្ញៀវចូលរួមត្រូវយករបស់របរឬអំណោយផ្សេងៗជូននិងជួយដល់គ្រួសារសព។ ទំនៀមទម្លាប់នេះត្រូវគេប្រតិបត្តិនៅតាមបណ្ដាប្រទេសកាន់សាសនាអ៊ិស្លាមដទៃទៀត ពិសេសប្រទេសពិភពអារ៉ាប់ [១៤]។ ចំណែកឯ នៅសហគមន៍ខ្មែរអ៊ិស្លាម(ជ្វា) ក៏ដូចគ្នានឹងសហគមន៍ចាមដទៃទៀតនៅកម្ពុជាដែរ គឺមិនអាចប្រតិបត្តិដូចនឹងបណ្ដាប្រទេសពិភពអារ៉ាប់នោះទេ ដោយគ្រួសារសពតែងគិតពីភ្ញៀវដែលមកចូលរួម ហើយតែងចាត់ចែងធ្វើម្ហូបអាហារជា បាយ សម្ល ឬបបរ សម្រាប់ទទួលភ្ញៀវ។

រហូតមកដល់បច្ចុប្បន្ននេះ សហគមន៍ខ្មែរអ៊ិស្លាមនៅឃុំព្រៃថ្នងនៅបានប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវកិច្ចពិធីជូនដំណើរសពនិងរបៀបនៃការទុកដាក់សព។ កិច្ចពិធីជូនដំណើរសពនិងរបៀបទុកដាក់សព មានជាអាទិ៍ ការរុំសពនឹងសំពត់(មិនប្រើមឈូស) កិច្ចពិធីថ្វាយបង្គំព្រះសុំខមាទោស និង ការបញ្ចុះសព(មិនបូជា)។

ជាការប្រតិបត្តិ គេតែងចំអាសសាកសព(ងូតទឹកសម្អាតសព) មុនពេលរុំបិទបាំងរាងកាយសពនឹងសំពត់។ គេអាចប្រើសំពត់ពណ៌សឬពណ៌ខ្មៅដើម្បីរុំសាកសពឱ្យជិត ដោយគេត្រូវរុំបីជាន់។ ក្នុងមួយជាន់ៗ គេប្រើកំណាត់សំពត់ដាច់ដោយឡែកគ្នា និង ត្រូវរុំបីជុំខ្លួនសពក្នុងមួយជាន់។ បន្ទាប់ពីរុំសាកសពរួចហើយ គេត្រូវចងលើសំពត់រុំសពនោះបន្ថែមទៀត។ សហគមន៍ខ្មែរអ៊ិស្លាមនៅឃុំព្រៃថ្នងនៅរក្សាបានការប្រតិបត្តិបែបនេះយ៉ាងខ្ជាប់ខ្ជួន ដោយមិនប្រើមឈូសដាក់រក្សាសពឡើយ។

ជាកិច្ចពិធីបន្ទាប់ គេសែងសាកសពទៅវិហារដើម្បីថ្វាយបង្គំសុំខមាទោសនិងទទួលពរជ័យពីព្រះជាម្ចាស់។ កិច្ចពិធីនេះមានការចូលរួមពីញាតិសន្ដាននិងចាស់ទុំក្នុងសហគមន៍ផងដែរ។ ក្នុងករណីផ្ទះរបស់សពស្ថិតនៅឆ្ងាយពីវិហារ គេអាចធ្វើកិច្ចថ្វាយបង្គំសុំខមាទោសនិងទទួលពរជ័យពីព្រះនៅតាមវាលស្រែ ឬទីដ៏សមគួរណាមួយក៏បាន។ ជាទូទៅ គេចំណាយពេលវេលាថ្វាយ

[១៤] ម៉ាន ម៉ាត់ ប្រធានសមាគមម៉ូស្លីមអះម៉ាឌីយ៉ាកម្ពុជា។ (សម្ភាសន៍ថ្ងៃទី៩ ខែកុម្ភៈឆ្នាំ២០១៧)។

*បង្គំព្រះនេះប្រមាណពីរនាទី ហើយទើបប្រកាសអញ្ជើញចាស់ទុំនិងញាតិមិត្តទាំងឡាយចូលរួមសែងដង្ហែជូនដំណើរសពទៅទីបញ្ចុះដែលបានកំណត់និងរៀបចំរួចហើយ។ ជាទូទៅ សហគមន៍ខ្មែរអ៊ិស្លាមមានទីបញ្ចុះសពរួម ហើយស្ថិតនៅទីទួលដែលមិនលិចទឹកនៅរដូវវស្សា។*



*សម្ភារៈសម្រាប់សែងសពរបស់សហគមន៍ខ្មែរអ៊ិស្លាម(ជ្វា)នៅឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត*

*សពសាសនិកអ៊ិស្លាមទាំងអស់(ទាំងសពបុរស ទាំងសពនារី) ត្រូវទុកដាក់ដោយការបញ្ចុះ មិនត្រូវការបូជានោះទេ។ សពសាសនិកអ៊ិស្លាមត្រូវបញ្ចុះដោយដាក់ក្បាលទៅទិសខាងជើង និងបែរមុខទៅទិសខាងលិច។ មានការលើកឡើងថា ការបញ្ចុះសពសាសនិកអ៊ិស្លាមបែបនេះគឺដោយសារសពព្រះមហាម៉ាត់ត្រូវតម្កល់បែបនេះដែរ ហើយដែលអ្នកគោរពប្រតិបត្តិតាមមហាម៉ាត់ត្រូវតែអនុវត្តតាមបែបនេះដែរ [១៥]។ ជាមួយគ្នានេះ ការដាក់តម្កល់សពសាសនិកអ៊ិស្លាមក្បាលទៅទិសខាងជើងនិងបែរមុខទៅទិសខាងលិច គឺដើម្បីដាក់តម្កល់ឱ្យសពបែរមុខទៅរកទីក្រុងម៉ាកាស់ដែលជាទីនៃស្រុកកំណើតព្រះនៃសាសនាអ៊ិស្លាម [១៦] និងជាទីក្រុងប្រារព្ធពិធីបុណ្យហាជី(បុណ្យកាប់គោ)នៃអ៊ិស្លាមសាសនាដ៏ធំបំផុតរៀងរាល់ឆ្នាំលើពិភពលោក។ សាសនិកអ៊ិស្លាម ជាពិសេសអ្នកមានជីវភាពសមរម្យ តែងប្រកាន់ខ្ជាប់នៅក្នុងគំនិតថា គេត្រូវទៅចូលរួមពិធីបុណ្យហាជីនៅទីក្រុងម៉ាកាស់យ៉ាងហោចម្តងក្នុងមួយជីវិតរបស់គេ។ ការប្រតិបត្តិការថ្វាយបង្គំប្រចាំថ្ងៃរបស់សាសនិកអ៊ិស្លាមនៅកម្ពុជា ក៏ថ្វាយបង្គំបែរមុខទៅទិសខាងលិចដែរ។*

[១៥] *ម៉ាន ម៉ាត់* ប្រធានសមាគមម៉ូស្លីមអះម៉ាឌីយ៉ានៅកម្ពុជា។ (សម្ភាសន៍ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧)

[១៦] *ម៉ាន ម៉ាត់* ប្រធានសមាគមម៉ូស្លីមអះម៉ាឌីយ៉ានៅកម្ពុជា។ (សម្ភាសន៍ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧)

ក្នុងការបញ្ចុះសពសាសនិកអិស្លាមដាក់ក្បាលទៅទិសខាងជើងនិងមុខបែរទៅទិសខាងលិច គឺរណ្ដៅផ្នូរសពសាសនិកអិស្លាមមានលក្ខណៈពិសេសដោយឡែករបស់ខ្លួន។ នៅពេលគេជីករណ្ដៅផ្នូរដល់ទីជម្រៅដែលគេចង់បានហើយ គេចោះរូងដីទៅផ្នែកម្ខាងនៃជញ្ជាំងរណ្ដៅដែលជាទីកន្លែងត្រូវដាក់តម្កល់សាកសព។ គេដាក់តម្កល់សពនៅក្នុងទីចោះរូងដីម្ខាងនោះ ដោយដាក់ក្បាលសពទៅទិសខាងជើងនិងផ្អៀងខ្លួនសពបែរមុខទៅទិសខាងលិច ហើយមានបន្ទះក្ដារសម្រាប់បិទទប់(គេតែងប្រើឬស្សីនៅរវាងបន្ទះក្ដារនិងសពជួយទប់បន្ថែមទៀត)រូងដីចោះនោះ ដើម្បីរក្សាស្ថានភាពសពឱ្យនៅផ្អៀងខ្លួននិងបែរមុខទៅទិសខាងលិច រួចទើបគេលុបរណ្ដៅផ្នូរនោះ។ ដូច្នេះ រណ្ដៅដែលគេជីកត្រង់ពីលើទៅក្រោមនោះ មិនមានដាក់តម្កល់សពនោះទេ ហើយដីដែលគេលុបរណ្ដៅនោះ ក៏មិនបានលុបលើសាកសពនោះដែរ។

នៅទីរណ្ដៅបញ្ចុះសពក្នុងសហគមន៍នេះ មិនមានការពូនដីជាផ្នូរនោះទេ តែគេអាចធ្វើជារងទូលតិចៗដើម្បីកំណត់ចំណាំជាទីកន្លែងកប់សព។ នៅទីរណ្ដៅកប់សពនោះ មានដាក់សញ្ញាសម្គាល់ជាដុំថ្មឬឈើនៅខាងចុងក្បាលនិងខាងចុងជើង។ នៅសហគមន៍ខ្លះ ដុំថ្មឬដុំឈើនៅផ្នែកខាងក្បាល គេអាចមានចារជាអក្សរនូវឈ្មោះរបស់សព អាយុសពនិងថ្ងៃខែឆ្នាំទទួលមរណភាព។ តាមការអះអាងរបស់អ្នូង នៅខេត្តកំពង់ឆ្នាំង បាត់ដំបងនិងខេត្តកណ្ដាល បានឱ្យដឹងថា ប្រសិនបើដុំថ្ម ឬឈើដាក់ខាងក្បាលខ្ពស់ជាងខាងចុងជើងនោះបញ្ជាក់ថា វាជាផ្នូររបស់មនុស្សប្រុស និងផ្ទុយមកវិញ គឺជាផ្នូររបស់មនុស្សស្រី [១៧]។



ទីបញ្ចុះសពរួមរបស់សហគមន៍ខ្មែរអិស្លាម(ជ្វា)នៅឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត

សាសនិកខ្មែរអិស្លាមមិនមានទំនៀមទម្លាប់លើកសពនោះទេ ពោលគឺបើសពបញ្ចុះនៅទីណា នោះត្រូវដាក់នៅទីនោះរហូត ដោយមិនមានការគាស់កាយលើកសពនោះឡើយ។ សូម្បីសពបញ្ចុះនៅក្នុងរបបខ្មែរក្រហមក៏គេមិនមានការគាស់កាយរើសពទៅបញ្ចុះនៅទីតាំងផ្សេង ឬ

[១៧] មជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់ ៖ *ក្រុមជនជាតិភាគតិចនៅកម្ពុជា* បោះពុម្ពលើកទី២ ឆ្នាំ២០១៥ ទំព័រ១៣០។

យកជាតុដាក់រក្សាក្នុងកោដ្ឋដែរ[១៨]។ ទោះជាយ៉ាងណា ញាតិសន្តានរបស់សពអាចទៅសម្អាតនៅទីបញ្ចុះសពឬអាចថាជាការទៅសួរសុខទុក្ខសព នៅកំលុងពិធីបុណ្យធំៗទាំងបីរបស់សាសនាអិស្លាម គឺ បុណ្យហាជី(បុណ្យកាប់គោ) បុណ្យម៉ៅឡូត់ (បុណ្យខួបកំណើតព្រះ) និង បុណ្យរ៉ាម៉ាឌន (បុណ្យបួសតមចំណីអាហារ)។ នៅកំលុងពេលសម្អាតផ្នូរនេះ គេគ្រាន់តែមានកិច្ចសូត្រធម៌ថ្វាយបង្គំប៉ុណ្ណោះ ដោយមិនមានសែនទំចំណីអាហារនោះទេ។ ជាទូទៅ គេអាចទៅទីបញ្ចុះសពក្រោយពេលថ្វាយបង្គំព្រះនិងពិសាអាហារនៃពិធីបុណ្យនៅវិហាររួចរាល់។ ការទម្លាប់ទៅសម្អាតផ្នូរសពញាតិសន្តាន ជាការអប់រំដល់អ្នកជំនាន់ក្រោយនូវរបៀបគោរពអ្នកជំនាន់មុន ពោលគឺក្នុងន័យថា ថ្ងៃនេះយើងមកសម្អាតផ្នូរឱ្យគេ ថ្ងៃក្រោយគេនឹងមកសម្អាតផ្នូរឱ្យខ្លួនយើងវិញ។

ជាទូទៅ សហគមន៍ខ្មែរអិស្លាមតែងមានទីបញ្ចុះសពរួមសម្រាប់សាសនិកអិស្លាមនៅតាមសហគមន៍នីមួយៗ។ ទីបញ្ចុះសពរួមនេះ គឺបានមកពីការបរិច្ចាគទានពីអ្នកមានដីធំៗ អ្នកមានដីភោគច្ឆូរជារ។ ការបរិច្ចាគដីធ្វើឡើងដោយការប្រកាសជាសាធារណៈនៅក្នុងវិហារ លើទីតាំងនិងទំហំដី។ បន្ទាប់ពីប្រកាសរួច ដីនោះនឹងក្លាយជាកម្មសិទ្ធិរួមរបស់សហគមន៍សម្រាប់បង្កើតជាទីបញ្ចុះសពរួម។

ទោះបីសពសាសនិកអិស្លាមសុទ្ធតែត្រូវបញ្ចុះនិងមិនមានបុណ្យលើកសពក្តី តែសាសនិកអិស្លាមមិនយល់ថា នាពេលអនាគត សហគមន៍ប្រឈមនឹងកង្វះដីសម្រាប់បញ្ចុះសពនោះទេ ដោយសារសនិកអិស្លាមអាចបញ្ចុះសពជាន់លើគ្នានៅទីតាំងដដែល បន្ទាប់ពីចាក់ដីកម្ពស់ប្រមាណ ១,៥ម៉ែត្រពីលើផ្នូរសពដំបូង។ «ឧទាហរណ៍ លើកទី១ គេបញ្ចុះសពក្នុងស្រែ។ នៅពេលបញ្ចុះសពក្នុងស្រែរួមរបស់គេពេញអស់ហើយ គេអាចបញ្ចុះសពលើកទី២លើស្រែនោះបានទៀត បន្ទាប់ពីគេចាក់ដីមួយម៉ែត្រកន្លះពីលើនោះរួច»[១៩]។

## ២.៤. ការប្រតិបត្តិសាសនា

### ក. វិហារ និង សារ៉ាវ

វិហារជាទីគោរពសក្ការៈសម្រាប់សាសនិកអិស្លាម។ វាជាទីថ្វាយបង្គំព្រះប្រចាំថ្ងៃរបស់សាសនិកអិស្លាមក្នុងសហគមន៍ ជាទីប្រតិបត្តិពិធីសាសនា(អិស្លាម)ផ្សេងៗ និង ជាទីជួបជុំសម្រាប់

[១៨] *ស្លេះ ហ្គោសាលី* គ្រូបង្រៀនផ្នែកសាសនាអ៊ិស្លាមនៅសហគមន៍ព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១៧)

[១៩] *ស្លេះ ហ្គោសាលី* គ្រូបង្រៀនផ្នែកសាសនាអ៊ិស្លាមនៅសហគមន៍ព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១៧)

កិច្ចការងារផ្សេងៗក្នុងសហគមន៍ ដូចជា ការងារមនុស្សធម៌ ជាដើម។ ជាទូទៅ វិហារអ៊ិស្លាមសាងសង់ឡើងតាមស្ថាបត្យកម្មនិងរចនាបទបែបអារ៉ាប់។



វិហារម៉ាស្ជិទនូរុលអ៊ាសសាននៃបរិស័ទខ្មែរអ៊ិស្លាម នៅភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត

សារ៉ាវ(ភាសាម៉ាឡេ) ជាទីស្នាក់ការថ្វាយបង្គំព្រះរបស់សាសនិកអ៊ិស្លាមក្នុងសហគមន៍។ សារ៉ាវមានតួនាទីជួយសម្រួលដល់សាសនិកអ៊ិស្លាមក្នុងការថ្វាយបង្គំព្រះប្រចាំថ្ងៃ (ប្រាំដងក្នុងមួយថ្ងៃ) ដោយអាចថា វិហារស្ថិតនៅឆ្ងាយ ឬបរិស័ទពិបាកធ្វើដំណើរទៅវិហារជាដើម។ ប៉ុន្តែ នៅរៀងរាល់ថ្ងៃសុក្រ សាសនិកអ៊ិស្លាមត្រូវទៅថ្វាយបង្គំព្រះរួមគ្នានៅវិហារ(មិនមានការថ្វាយបង្គំនៅសារ៉ាវ នៅថ្ងៃសុក្រទេ) ដើម្បីទទួលការណែនាំផ្សេងៗពីសង្គ្រាជ។ សារ៉ាវប្រៀបបានជាទីសក្ការៈរណបរបស់វិហារដែរ ដោយសារ៉ាវមិនមានតួនាទីប្រតិបត្តិពិធីសាសនាធំៗក្នុងសហគមន៍ដូចវិហារឡើយ។ ជាទូទៅ សារ៉ាវសាងសង់ឡើងដោយមានទ្រង់ទ្រាយស្រដៀងគ្នានឹងវិហារដែរ តែតូចជាងវិហារ។ នៅក្នុងស្រុកទឹកឈូ ខេត្តកំពត មានសារ៉ាវប្រមាណ៣៦ ។



សារ៉ាវនៅសហគមន៍ខ្មែរអ៊ិស្លាមឃុំព្រៃថ្នង

## ខ. ការប្រតិបត្តិថ្វាយបង្គំព្រះ

*ថ្វាយបង្គំព្រះ* ដែលភាសាអារ៉ាប់ហៅថា *សឡាត* ហើយភាសាម៉ាឡេហៅថា *សំយ៉ាំង* គឺជាកាតព្វកិច្ចរបស់សាសនិកអ៊ិស្លាមគ្រប់រូប(ទាំងពីរភេទ) ចាប់ពីពេលពេញវ័យ [២០] ឬចាប់កំណត់ពីអាយុ ១៥ឆ្នាំឡើងទៅ។ តាមច្បាប់សាសនាអ៊ិស្លាម សាសនិកអ៊ិស្លាមគ្រប់រូបត្រូវថ្វាយបង្គំព្រះជារៀងរាល់ថ្ងៃ ហើយមួយថ្ងៃត្រូវថ្វាយបង្គំ៥(ប្រាំ)ដង។ សាសនិកអ៊ិស្លាមនៅកម្ពុជា ទាំងសាសនិកខ្មែរអ៊ិស្លាមជ្វា ទាំងសាសនិកខ្មែរអ៊ិស្លាមចាម សុទ្ធសឹងប្រតិបត្តិការថ្វាយបង្គំព្រះប្រាំដងក្នុងមួយថ្ងៃ និងជារៀងរាល់ថ្ងៃ លើកលែងតែសហគមន៍ចាមក្រុមកនអ៊ីម៉ាំសាន់ដែលថ្វាយបង្គំព្រះតែម្ដងក្នុងមួយសប្ដាហ៍ គឺនៅថ្ងៃសុក្រ។

ការប្រតិបត្តិថ្វាយបង្គំប្រាំដងក្នុងមួយថ្ងៃមាន នៅពេលព្រឹកក្នុងរង្វង់ម៉ោង៥ ពេលថ្ងៃត្រង់ក្នុងរង្វង់ម៉ោង១២ ពេលរសៀលម៉ោង ៣៖៣០នាទី ពេលព្រលប់ក្នុងរង្វង់ម៉ោង ៦ និង ក្រោយម៉ោង ៧ ឡើងទៅ។ ជាទូទៅ មុនការប្រតិបត្តិថ្វាយបង្គំ សាសនិកអ៊ិស្លាមត្រូវលាងសម្អាតកាយ ដូចជា លាងដៃ លាងជើង និង លាងមុខ ជាដើម ដើម្បីឱ្យរូបកាយស្អាតជ្រះស្រឡះនិងចិត្តបរិសុទ្ធមុនពេលចូលវិហារ។ ក្នុងការថ្វាយបង្គំមួយលើកៗមានរយៈពេលប្រមាណ ១០នាទី តែវាក៏អាស្រ័យទៅតាមអ្នកថ្វាយបង្គំដែរ ដោយអ្នកខ្លះចង់ថ្វាយបង្គំយូរ គេអាចសូត្រធម៌ឱ្យវែង។

ការថ្វាយបង្គំព្រះអាចប្រតិបត្តិនៅព្រះវិហារ សារ៉ាវ ផ្ទះ ទីរៀបចំពិសេសដោយឡែកសម្រាប់សាសនិកអ៊ិស្លាម (musallas) ឬទីដ៏សមគួរមួយតាមស្ថានភាពជាក់ស្ដែង។ ទោះជាយ៉ាងណា មានការលើកឡើងថា សម្រាប់បុរស ការគោរពថ្វាយបង្គំនៅវិហារនឹងទទួលបានបុណ្យច្រើនជាងការគោរពថ្វាយបង្គំនៅតាមផ្ទះ [២១]។ នៅក្នុងសហគមន៍ខ្មែរអ៊ិស្លាម ឃុំព្រៃថ្នង បុរសត្រូវមកថ្វាយបង្គំព្រះនៅវិហារ នៅរៀងរាល់ថ្ងៃសុក្រ ដើម្បីទទួលបានការអប់រំណែនាំពីសង្គ្រាជវិហារឬពីអ្នកតំណាងដែលចាត់តាំងដោយសង្គ្រាជវិហារ។ ជាទូទៅ ការបញ្ជ្រាបអប់រំណែនាំនេះ តែងធ្វើឡើងនៅកំលុងពេលនៃការថ្វាយបង្គំព្រះនៅវេលាថ្ងៃត្រង់ម៉ោង១២ ដោយមានខ្លឹមសារផ្ដោតជាសំខាន់ទៅលើការប្រតិបត្តិប្រចាំថ្ងៃរបស់សាសនិកអ៊ិស្លាមដែលប្រាសចាកពីការណែនាំក្នុងច្បាប់

---

[២០] ការកំណត់សម្គាល់ភាពពេញវ័យ៖ ស្ត្រីគិតចាប់ពីពេលមានរដូវ(ពេញវ័យរៀបការ) ឯបុរសគិតចាប់ពីពេលចេះយល់សប្ដិមានទឹកកាម។

[២១] លី ហ្សាកុប ហាកីមវិហារ(សង្គ្រាជ) អាល់ម៉ាក់មូរ នៅភូមិច្រករមៀត ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ (សម្ភាសន៍ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧)។

សាសនា មានជាអាទិ៍ ការសេពគ្រឿងស្រវឹង ការសេពគ្រឿងញៀន និង ការប្រព្រឹត្តអំពើអបាយមុខផ្សេងៗ ជាដើម។

ចំណែកឯ សាសនិកអ៊ិស្លាមនារីមិនមានកាតព្វកិច្ចប្រតិបត្តិការថ្វាយបង្គំព្រះនៅវិហារដូចបុរសទេ ហើយជាទូទៅ ពួកគាត់តែងប្រតិបត្តិការថ្វាយបង្គំនៅផ្ទះ។ «សម្រាប់ស្រីៗ ការថ្វាយបង្គំនៅវិហារមិនមែនជាកាតព្វកិច្ចដូចខាងប្រុសៗនោះទេ ដោយស្រីៗថ្វាយបង្គំនៅផ្ទះល្អជាងការថ្វាយបង្គំនៅវិហារ។ ស្រីៗអាចថ្វាយបង្គំនៅក្នុងវិហារបានលុះត្រាតែមានកន្លែងទំនេរ ហើយត្រូវបាំងវាំងននខណ្ឌបិទមិនឱ្យមើលឃើញគ្នាជាមួយខាងបុរសឡើយ ដើម្បីឱ្យស្ងប់អារម្មណ៍សំដៅតែលើព្រះប៉ុណ្ណោះ»[២២]។ ការថ្វាយបង្គំព្រះបានចាត់ទុកថា ជាការតាំងសមាធិដើម្បីរំងាប់អារម្មណ៍កុំឱ្យអ្នកប្រតិបត្តិគិតរឿងលោកិយច្រើនពេក ហើយដែលសាសនិកអ៊ិស្លាមភាគច្រើនសុទ្ធសឹងបានយល់រឿងនេះ។ ចំពោះសាសនិកអ៊ិស្លាមដែលមិនបានរៀនសូត្រច្រើនខាងសាសនា នោះពួកគេអាចប្រតិបត្តិដោយមិនយល់ពីអត្ថន័យរបស់វាដែរ ដោយពួកគេគ្រាន់តែប្រតិបត្តិតៗគ្នាតាមលំអានប្រពៃណីដែលបានបន្សល់ទុកឱ្យ។

ការរឹតត្បិតនារីក្នុងការប្រតិបត្តិការថ្វាយបង្គំព្រះនៅក្នុងវិហារ ធ្វើឱ្យគេកម្រឃើញមានវត្តមាននារីថ្វាយបង្គំព្រះនៅក្នុងវិហារណាស់។ ជាក់ស្តែង នៅវិហារម៉ាស្ជិទទួរុលអ៊ិសសាននៃបរិស័ទខ្មែរអ៊ិស្លាម នៅភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត ដែលមានលក្ខណៈធំទូលាយនិងមានទីទំនេរច្រើននោះ ក៏មិនឃើញមានវត្តមានសាសនិកអ៊ិស្លាមនារីចូលថ្វាយបង្គំឡើយ ហើយក៏ពុំឃើញមានការបិទបាំងវាំងននរក្សាទុកសម្រាប់នារីដែរ។ ចំពោះចំណុចនេះ នារីៗក្នុងសហគមន៍នេះបានបញ្ជាក់ថា ការថ្វាយបង្គំព្រះនៅក្នុងវិហារមិនមែនជាកាតព្វកិច្ចរបស់ពួកគាត់នោះទេ ដោយពួកគាត់ថ្វាយបង្គំនៅផ្ទះក៏បាន ហើយពួកគេក៏មិនមានការអាក់អន់ចិត្តនោះដែរ ព្រោះនេះជាច្បាប់ក្នុងសាសនាដែលបានតម្រូវឱ្យបុរសជាគោលសំខាន់ក្នុងការបំពេញនូវកាតព្វកិច្ចនេះ។

ទោះបីជាយ៉ាងណា ពួកគាត់(ក្រុមនារី)តែងមកថ្វាយបង្គំព្រះក្នុងវិហារនៅរដូវបុណ្យរ៉ាម៉ាឌន(ខែបួសតមចំណីអាហារ)ដែលប្រព្រឹត្តទៅក្នុងមួយឆ្នាំម្តង និងមានរយៈពេលមួយខែ។ គួរបញ្ជាក់ថា ការប្រតិបត្តិថ្វាយបង្គំព្រះ ទាំងចំពោះសាសនិកអ៊ិស្លាមបុរស ទាំងចំពោះសាសនិក-អ៊ិស្លាមនារី គឺមួយថ្ងៃប្រាំពេលដូចគ្នា គ្រាន់តែបុរសប្រតិបត្តិថ្វាយបង្គំនៅក្នុងវិហារ ឯនារីប្រតិបត្តិការថ្វាយបង្គំនៅផ្ទះ។ នៅកំលុងពេលបួសបុណ្យរ៉ាម៉ាឌន ការថ្វាយបង្គំព្រះត្រូវបន្ថែមមួយដងទៀតលើការប្រតិបត្តិមួយថ្ងៃថ្វាយបង្គំប្រាំដង ពោលគឺសាសនិកអ៊ិស្លាមត្រូវថ្វាយបង្គំព្រះ៦(ប្រាំ

[២២] សឹម ឡៃម៉ាន គ្រូបង្រៀនក្មេងៗអ៊ិស្លាមនៅសហគមន៍ព្រៃថ្នង ស្រុកទឹកឈូ ខេត្ត កំពត ឆ្នាំ២០១៧។ (សម្ភាសន៍ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១៧)។

មួយ)ដង ក្នុងកំលុងពេលបួសរ៉ាម៉ាឌនរយៈពេលមួយខែ។ ច្បាប់សាសនាអ៊ិស្លាមចែងថា អ្នកថ្វាយបង្គំព្រះក្នុងខែបួសនេះនឹងត្រូវព្រះជាម្ចាស់រៀបចំកន្លែងមួយទុកឱ្យនៅក្នុងឋានសួគ៌។



សាសនិកខ្មែរអ៊ិស្លាមនារីនៅផ្នែកខាងមុខនៃវិហារម៉ាស្ជិទនូរុលអ៊ិសសាន
(ភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត)

ខាងក្រោមនេះជារូបភាពបរិស័ទសហគមន៍ខ្មែរអ៊ិស្លាម(ជ្វា)នៅឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត ក្នុងការថ្វាយបង្គំព្រះក្នុងវិហារ ដែលការប្រត្តិបត្តិថ្វាយបង្គំមានបួនជំហានៈ ជំហានទី១ គឺ ឈរ, ជំហានទី២ ឱនច្រត់ក្បាលជង្គង់, ជំហានទី៣ លត់ជង្គង់ និង ជំហានទី៤ ឱនក្រាបចុះ។



ការសម្អាតកាយនៃបរិស័ទបុរសខ្មែរអ៊ិស្លាម មុនពេលចូលថ្វាយបង្គំក្នុងវិហារ




ជំហានទី១ ជំហានទី២




ជំហានទី៣ ជំហានទី៤

## សេចក្តីសន្និដ្ឋាន

សាសនិកអ៊ិស្លាមដែលមានប្រវត្តិរស់នៅលើទឹកដីកម្ពុជាជាយូរមកហើយនោះ គឺមិនមែនមានតែជនជាតិចាមដែលមានប្រភពកំណើតនៅប្រទេសចម្ប៉ានោះទេ តែនៅមានជនជាតិជ្វាដែលបានធ្វើអន្តោប្រវេសន៍ពីកោះជ្វា ប្រទេសឥណ្ឌូនេស៊ី មករស់នៅកម្ពុជាតាមតំបន់មាត់សមុទ្រជាពិសេសនៅខេត្តកំពតដែរ។ ក្រុមសាសនិកអ៊ិស្លាម(ជ្វា)នៅខេត្តកំពតយល់ថា ក្រុមខ្លួនបច្ចុប្បន្នមានឈាមជ័រជាខ្មែរដែរ ហើយចូលចិត្តហៅខ្លួនឯងជា ខ្មែរអ៊ិស្លាម ដែលជាបញ្ញត្តិបង្កើតឡើងដោយសម្តេចព្រះនរោត្តម សីហនុ ក្នុងសម័យសង្គមរាស្ត្រនិយម។ ក្រុមនេះរស់នៅដោយផ្សារភ្ជាប់យ៉ាងជិតស្និទ្ធនឹងប្រជាជនខ្មែរ ហើយចេះនិយាយភាសាខ្មែរដូចខ្មែរដែរ។

ជាមូលដ្ឋាន សហគមន៍ខ្មែរអ៊ិស្លាមនៅឃុំព្រៃថ្នងនៅប្រតិបត្តិទំនៀមទម្លាប់ប្រពៃណីតាមបែបសាសនាបានច្រើន មានជាអាទិ៍ ការថ្វាយបង្គំព្រះ៥ដងក្នុងមួយថ្ងៃ ការរៀបអាពាហ៍ពិពាហ៍ និង ការរៀបកិច្ចពិធីជូនដំណើរសពនិងការទុកដាក់សព។ សហគមន៍នៅរក្សាប្រតិបត្តិកិច្ចពិធីប្រគល់កូនក្រមុំឱ្យកូនកំលោះ ដែលជាកិច្ចពិធីសំខាន់ជាមូលដ្ឋាននៃការរៀបអាពាហ៍ពិពាហ៍ក្នុង

សហគមន៍នេះ នៅប្រតិបត្តិរក្សាការទុកដាក់សពដោយការរុំនឹងសំពត់និងរុងដីក្នុងរណ្ដៅផ្នូរដាក់សព ពេលដែលនៅសហគមន៍អ៊ិស្លាមខ្លះបានប្រើមឈូសដាក់សពទៅហើយ។

ចំណែក យុវជនសាសនិកអ៊ិស្លាមក្នុងសហគមន៍ហាក់មានទំនោរដើរទៅតាមការវិវត្តរបស់សង្គម។ ពួកគេចូលចិត្តប្រតិបត្តិតាមភាពទំនើបនៃសង្គម ចូលចិត្តស្លៀកពាក់តាមរបៀបទាន់សម័យដែលប្រាសចាកទំនៀមទម្លាប់បែបសាសនាដែលតម្រូវឱ្យស្ត្រីស្លៀកពាក់បិទជិតរាងកាយ។ ដោយពួកគេនិយាយភាសាខ្មែរយ៉ាងស្ទាត់ជំនាញដូចខ្មែរផង ដោយសារពួកគេស្លៀកពាក់ធម្មតាដូចខ្មែរផង ដូច្នេះ គេពិបាកកំណត់អត្តសញ្ញាណយុវជនណាជាសាសនិកអ៊ិស្លាម តាមរយៈលក្ខណៈខាងក្រៅនេះណាស់។ ទោះបីជាយ៉ាងណា ក៏ពួកគេនៅតែចូលរួមទទួលការអប់រំអំពីច្បាប់វិន័យសាសនា ហើយនៅតែគោរពប្រតិបត្តិសាសនាអ៊ិស្លាមជាសាសនារបស់ខ្លួន។

## ឯកសារពិគ្រោះ

*ឯកសារស្នាដៃ*


- មជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់ ៖ *ក្រុមជនជាតិភាគតិចនៅកម្ពុជា* បោះពុម្ពលើកទី២ ឆ្នាំ២០១៥។
- ហ្សង់ មីសែល ហ្វីលីពី ៖ *ការស្រាវជ្រាវបឋមអំពីភាសាជនជាតិភាគតិចនៅកម្ពុជា* បោះពុម្ពឆ្នាំ២០០៩។


*កិច្ចសម្ភាសន៍*

- ម៉ាន ម៉ាត់ ប្រធានសមាគមម៉ូស្លីមអះម៉ាឌីយ៉ានៅកម្ពុជា។ (សម្ភាសន៍ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧)
- លី ហ្សាកុប ហាគីមវិហារ(សង្ក្រាជ) អាល់ម៉ាក់មូរ នៅភូមិច្រករមៀត ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ (សម្ភាសន៍ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧)
- លី សារី គណៈអ៊ីម៉ាំខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧)
- ស្មេះ ហ្គោសាលី គ្រូបង្រៀនផ្នែកសាសនាអ៊ិស្លាមនៅសហគមន៍ព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧)
- សឹម ឡៃម៉ាន គ្រូបង្រៀនក្មេងៗអ៊ិស្លាមនៅសហគមន៍ព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧)

- សុខ សម៉ាឌុន អ៊ីម៉ាំវិហារនៅភូមិទ្វារថ្មី ស្រុកទឹកឈូ ខេត្តកំពត។ (សម្ភាសន៍ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧)



នាងខ្ញុំ(ម៉ិល វាសនា)ក្នុងកិច្ចសម្ភាសន៍សាសនិកខ្មែរអ៊ិស្លាមនារី
នៅវិហារម៉ាស្ជិទនូរុលអ៊ិសសាន
(ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧, ភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត)